

**Do you need help resolving a concern?**
**Information about support persons and advocates**

# តើអ្នកត្រូវការជំនួយក្នុងការដោះស្រាយកង្វល់ទេ?

## ព័ត៌មានអំពីអ្នកគាំទ្រ និងអ្នកតស៊ូមតិ

សៀវភៅណែនាំនេះជួយគ្រួសារ ឪពុកម្ដាយ អ្នកថែទាំ អ្នកគាំទ្រ និងអ្នកតស៊ូមតិឱ្យយល់ដឹងអំពីតួនាទីរបស់អ្នកគាំទ្រ និងអ្នកតស៊ូមតិ និងរបៀបដែលពួកគេអាចជួយក្នុងការប្រាស្រ័យទាក់ទង ឬលើកឡើងពីកង្វល់ជាមួយសាលារៀន ឬធ្វើបណ្ដឹងតវ៉ា។

មនុស្សមួយចំនួនមានការលំបាកជាងអ្នកផ្សេងទៀត ក្នុងការប្រាស្រ័យទាក់ទងគ្នា ឬលើកឡើងពីកង្វល់ជាមួយសាលារៀន។ វាអាចមានប្រយោជន៍ក្នុងការស្នើសុំឱ្យអ្នកផ្សេងជួយអ្នកក្នុងរឿងនេះ។

អ្នកណាម្នាក់ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ អាចធ្វើជាអ្នកគាំទ្រសម្រាប់ឪពុកម្ដាយ អ្នកថែទាំ សិស្ស ឬសមាជិកគ្រួសារ។ ឪពុកម្ដាយ អ្នកថែទាំ សិស្ស ឬសមាជិកគ្រួសារ ក៏អាចទាក់ទងសេវាកម្មអ្នកតស៊ូមតិដែលមានវិជ្ជាជីវៈសម្រាប់ការគាំទ្រផងដែរ។

ក្រសួងប្ដេជ្ញាដោះស្រាយកង្វល់នានាអំពីសាលារៀនរដ្ឋ NSW ក្នុងតំបន់កន្លែងណាដែលអាចធ្វើទៅបាន។ ទោះយ៉ាងណាក៏ដោយ ទម្រង់បែបបទបណ្ដឹងតវ៉ាតាមអនឡាញរបស់ក្រសួងអាចប្រើប្រាស់បានពេលណាបញ្ហាត្រូវការពន្លឿនបន្ថែមទៀត។

ប្រសិនបើមិនអាចដោះស្រាយបញ្ហាក្នុងតំបន់បានទេ អ្នកគាំទ្រ ឬអ្នកតស៊ូមតិអាចជួយធ្វើឱ្យដំណើរការកាន់តែងាយស្រួលនៅពេលធ្វើបណ្ដឹងតវ៉ា។ នេះរួមបញ្ចូលទាំងជំនួយ និងការគាំទ្រសមហេតុផលដើម្បីយល់ដឹងពី៖

- របៀបប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជាមួយសាលារៀន
- ដំណើរការដែលនឹងត្រូវបានអនុវត្តដើម្បីដោះស្រាយកង្វល់ ឬបណ្ដឹងតវ៉ា
- ពេលវេលាដែលទំនងជានឹងត្រូវចំណាយដើម្បីដោះស្រាយកង្វល់ ឬបណ្ដឹងតវ៉ា
- អ្វីនឹងកើតឡើងបន្ទាប់ និងនៅពេលណា
- អ្នកណាដែលត្រូវទាក់ទងប្រសិនបើមានសំណួរ ឬកង្វល់ណាមួយជាមួយនឹងដំណើរការ
- អ្វីដែលត្រូវធ្វើប្រសិនបើបុគ្គលដែលលើកឡើងពីកង្វល់ ឬបណ្ដឹងតវ៉ាមិនសប្បាយចិត្តនឹងវិធីដែលវាកំពុងត្រូវបានដោះស្រាយ ឬអំពីលទ្ធផលនោះ។

មិនគួរប្រើអ្នកគាំទ្រ ឬអ្នកតស៊ូមតិជាអ្នកបកប្រែផ្ទាល់មាត់ទេ។ ប្រសិនបើត្រូវការអ្នកបកប្រែផ្ទាល់មាត់សម្រាប់កិច្ចប្រជុំ ឬការសម្ភាសន៍ សាលារៀនអាចរៀបចំឱ្យមានសេវាកម្មសមស្រប។ អាស្រ័យលើភាពអាចរកបានសេវាកម្មបកប្រែផ្ទាល់មាត់អាចត្រូវបានផ្ដល់ជូននៅនឹងកន្លែង ឬតាមរយៈវីដេអូ ឬទូរសព្ទ។ សូមគ្រាន់តែសួរសាលារៀនជាមុនប៉ុណ្ណោះ។

មុនពេលអ្នកគាំទ្រ ឬអ្នកតស៊ូមតិទាក់ទិន វាអាចមានប្រយោជន៍ក្នុងការគិតអំពីតួនាទីរបស់ពួកគេ - តើពួកគេនៅទីនោះដើម្បីផ្ដល់ការគាំទ្រ និងជំនួយដល់បុគ្គលនោះតែប៉ុណ្ណោះ ឬក៏ពួកគេនៅទីនោះដើម្បីជួយស្វែងរកដំណោះស្រាយ?

### តួនាទីរបស់អ្នកគាំទ្រ

អ្នកគាំទ្រគឺជាបុគ្គលដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ដែលជួយក្នុងការដោះស្រាយបណ្ដឹងតវ៉ាដោយផ្ដល់ការគាំទ្រជាក់ស្ដែង និងផ្លូវចិត្តដល់បុគ្គលដែលធ្វើបណ្ដឹងតវ៉ា។ អ្នកគាំទ្រអាច៖

- ចូលរួមកិច្ចប្រជុំ
- និយាយនៅឯកិច្ចប្រជុំ ប្រសិនបើពួកគេមានព័ត៌មានដែលពាក់ព័ន្ធទៅនឹងស្ថានភាព
- ផ្ដល់ដំបូន្មានអំពីសិទ្ធិ និងសិទ្ធិទទួល
- បញ្ជាក់អំពីដំណើរការ ឬវិធានការ
- ស្នើសុំឱ្យផ្អាកក្នុងអំឡុងពេលប្រជុំ ដើម្បីគាំទ្របុគ្គល និងផ្ដល់ដំបូន្មាន ឬជំនួយ
- ធ្វើការសន្ទនាជាមួយអ្នកដែលលើកឡើងពីបណ្ដឹងតវ៉ាក្នុងអំឡុងពេលប្រជុំតាមសំណើរបស់ពួកគេ។
- ធ្វើការកត់សម្គាល់នានា
- ជួយក្នុងការអនុវត្តលទ្ធផល។

អ្នកគាំទ្រអាចសួរសំណួរ និងផ្ដល់ព័ត៌មាន។ ឧទាហរណ៍ ប្រសិនបើពួកគេចូលរួមដោយផ្ទាល់នៅក្នុងស្ថានភាពមួយ ហើយមានព័ត៌មានអំពីអ្វីដែលបានកើតឡើង ឬប្រសិនបើពួកគេមានគំនិតនានាអំពីផ្លូវនាំទៅរកភាពជោគជ័យ។

ប្រសិនបើអ្នកតំណាងផ្នែកច្បាប់កំពុងដើរតួជាអ្នកគាំទ្រ វាជារឿងសំខាន់ដែលពួកគេអនុញ្ញាតឱ្យបុគ្គលដែលលើកឡើងពីបញ្ហានោះ និយាយដោយខ្លួនឯង។

អ្នកគាំទ្រមានវត្តមាននៅទីនោះដើម្បីធ្វើជាសាក្សី ឬទីប្រឹក្សា។

វាមិនសមស្របចំពោះអ្នកគាំទ្រដើម្បីផ្ដល់ព័ត៌មាន ដែលបុគ្គលលើកឡើងពីបញ្ហានោះបានប្រាប់ពួកគេនោះឡើយ - តួនាទីរបស់អ្នកគាំទ្រគឺដើម្បីជួយបុគ្គលដែលលើកឡើងពីបញ្ហា ឬកង្វល់ដើម្បីប្រាប់រឿងរ៉ាវរបស់ពួកគេ។

## តួនាទីរបស់អ្នកតស៊ូមតិពីខាងក្រៅ

អ្នកតស៊ូមតិពីខាងក្រៅ គឺជានរណាម្នាក់ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ដែលត្រូវបានអនុញ្ញាតឱ្យនិយាយសម្រាប់បុគ្គលដែលលើកឡើងពីកង្វល់ ឬធ្វើបណ្ដឹងតវ៉ា ដើម្បីគាំទ្រដំណោះស្រាយវិជ្ជមានសម្រាប់បុគ្គលនោះ។ បុគ្គលនេះទំនងជាមកពីសេវាកម្មអ្នកតស៊ូមតិដែលមានវិជ្ជាជីវៈ។

ក្នុងករណីភាគច្រើន ពួកគេនឹងទាក់ទិននៅពេលបុគ្គលដែលលើកឡើងពីកង្វល់ មិនមានសមត្ថភាពក្នុងការប្រាស្រ័យទាក់ទង ឬរុករកស្ថានការណ៍ប្រកបដោយប្រសិទ្ធភាពដោយខ្លួនឯង។ បន្ថែមពីលើការផ្ដល់ជំនួយដូចគ្នានឹងអ្នកគាំទ្រផងដែរនោះ អ្នកតស៊ូមតិក៏អាច៖

- ផ្ដល់មតិយោបល់ណាមួយទៅក្នុងកិច្ចពិភាក្សាទាក់ទងនឹងបណ្ដឹងតវ៉ា និង
- យល់ព្រមចំពោះសកម្មភាពដែលកំពុងត្រូវបានចាត់វិធានការ ឬមិនបានចាត់វិធានការ។

## ធ្វើការជាមួយសាលារៀន - គន្លឹះមួយចំនួន

សាលារៀនចង់ដោះស្រាយបញ្ហាឱ្យបានឆាប់រហ័ស និងនៅកម្រិតមូលដ្ឋាន។ យើងលើកទឹកចិត្តឪពុកម្ដាយ អ្នកថែទាំ សមាជិកគ្រួសារ អ្នកគាំទ្រ និងអ្នកតស៊ូមតិ ឱ្យធ្វើការសហការគ្នាជាមួយបុគ្គលដែលគ្រប់គ្រងបញ្ហានេះ និងអ្នកតំណាងសាលា។ គន្លឹះ និងដំបូន្មានរបស់យើងសម្រាប់ការលើកឡើងពីកង្វល់ ឬបណ្ដឹងតវ៉ាប្រកបដោយប្រសិទ្ធភាព អាចជាកន្លែងមួយដ៏ល្អដើម្បីចាប់ផ្ដើម។

- វាអាចជួយផ្ដោតទៅលើហេតុការណ៍នានាដែលទាក់ទងនឹងកង្វល់ ឬបណ្ដឹងតវ៉ា និងលទ្ធផលសម្រាប់សិស្ស។
- ប្រាស្រ័យទាក់ទងដោយសុភាព និងស្ងប់ស្ងាត់។
- ខណៈពេលដែលបុគ្គលណាម្នាក់អាយុចាប់ពី១៨ឆ្នាំឡើងទៅ អាចគាំទ្រ ឬតស៊ូមតិសម្រាប់បុគ្គលដែលលើកឡើងពីកង្វល់ ឬបណ្ដឹងតវ៉ានោះ សាលារៀនអាចសម្រេចចិត្តមិនទាក់ទិនជាមួយបុគ្គលដែលត្រូវបានតែងតាំង ប្រសិនបើពួកគេមានហេតុផលសមហេតុផលមិនធ្វើដូច្នោះ។ ឧទាហរណ៍ ប្រសិនបើគេយល់ឃើញដោយសមហេតុផលថា បុគ្គលនោះអាចបង្កហានិភ័យដល់សុខភាព ឬសុវត្ថិភាពរបស់អ្នកដទៃ ឬកន្លែងដែលសិទ្ធិទទួលបានព័ត៌មានអំពីកុមារ ត្រូវបានដាក់កំហិតដោយច្បាប់។
- ជាទូទៅ បុគ្គលម្នាក់នឹងត្រូវបានតែងតាំងដើម្បីគ្រប់គ្រងដំណើរការក្នុងការលើកឡើងពីកង្វល់ ឬធ្វើបណ្ដឹងតវ៉ា។ នៅសាលារៀន បុគ្គលនោះអាចជានាយកសាលា ឬសមាជិកផ្សេងទៀតនៃបុគ្គលិកសាលា។
- សាលារៀនអាចសម្រេចចិត្តឱ្យមានបុគ្គលផ្សេងទៀតមានវត្តមាននៅក្នុងកិច្ចប្រជុំ ដើម្បីគាំទ្របុគ្គលិក ដើម្បីផ្ដល់ដំបូន្មានអ្នកជំនាញក្នុងការពិភាក្សា សង្កេត ឬកត់ត្រា។
- លុះត្រាតែមានការយល់ព្រមផ្សេងពីនេះ ព័ត៌មានលម្អិតទាំងអស់នៃបណ្ដឹងតវ៉ា និងដំណោះស្រាយគួរតែរក្សាការសម្ងាត់។

មានពេលខ្លះដែលបុគ្គលដែលត្រូវបានតែងតាំងជាអ្នកគាំទ្រ ឬអ្នកតស៊ូមតិ ប្រហែលជាមិនមែនជាមនុស្សល្អបំផុតក្នុងការទាក់ទិនក្នុងដំណើរការដោះស្រាយនោះទេ។ ឧទាហរណ៍៖

- នៅពេលដែលអ្នកគាំទ្រ ឬអ្នកតស៊ូមតិបានទាក់ទិនដោយផ្ទាល់នៅក្នុងស្ថានភាពនោះ ហើយប្រហែលជាមិនអាចបំពេញមុខការដើម្បីជាផលប្រយោជន៍ល្អបំផុតរបស់អ្នកដែលលើកឡើងពីកង្វល់ ឬធ្វើបណ្ដឹងតវ៉ានោះទេ។
- ប្រសិនបើដៃគូ ឬសមាជិកគ្រួសារកំពុងត្រូវបានចាត់ទុកថាជាអ្នកគាំទ្រ ឬអ្នកតស៊ូមតិ នេះគួរតែចងចាំថា ព័ត៌មានផ្ទាល់ខ្លួនអាចត្រូវបានលាតត្រដាងក្នុងអំឡុងពេលប្រជុំ ដែលពួកគេប្រហែលជាមិនបានដឹងពីមុនមក។

ការប្រជុំ ឬការពិភាក្សាអាចត្រូវបានបញ្ចប់ ប្រសិនបើបុគ្គលណាម្នាក់មានអាកប្បកិរិយាមិនសមហេតុផល ឬមិនអាចទទួលយកបាន។ អាកប្បកិរិយាមិនអាចទទួលយកបានអាចរួមបញ្ចូល ប៉ុន្តែអាចមានលើសពីនេះ៖

- ភាសាគ្រោតគ្រាត ឬជេរប្រមាថ រួមទាំងការប្រើពាក្យអាសអាភាស និងការធ្វើអត្ថាធិប្បាយប្រកាន់ភេទ ពូជសាសន៍ ឬប្រមាថមើលងាយ
- សកម្មភាពឈ្លានពាន ឬការបំភិតបំភ័យ ដូចជាអំពើហិង្សា និងកាយវិការគំរាមកំហែង
- បង្វែរការប្រជុំចេញពីគោលបំណងដែលបានបញ្ជាក់
- ការប្រាស្រ័យទាក់ទងមិនសមរម្យ និងខ្ជះខ្ជាយពេលវេលា
- ធ្វើកំណត់ត្រាជាអេឡិចត្រូនិចនៃការប្រជុំ ឬការហៅទូរសព្ទដោយគ្មានការយល់ព្រមពីមនុស្សទាំងអស់ ដែលកំពុងចូលរួមក្នុងការប្រជុំ ឬការហៅទូរសព្ទ។

## ព័ត៌មានបន្ថែម

សម្រាប់ព័ត៌មានបន្ថែម សូមមើលគន្លឹះ និងដំបូន្មានរបស់យើងសម្រាប់ការធ្វើបណ្ដឹងតវ៉ាប្រកបដោយប្រសិទ្ធភាព និងការណែនាំយោងឆាប់រហ័សក្នុងការធ្វើបណ្ដឹងតវ៉ាអំពីសាលារៀនរបស់យើង។

## សេវាអ្នកបកប្រែតាមទូរសព្ទ

សូមទាក់ទងសាលារៀន ប្រសិនបើអ្នកចង់បានព័ត៌មានបន្ថែម។ ប្រសិនបើអ្នកត្រូវការជំនួយអ្នកបកប្រែផ្ទាល់មាត់ ដើម្បីទាក់ទងមកសាលារៀន សូមទូរសព្ទលេខ 131 450 ដោយប្រាប់ពួកគេពីភាសាដែលអ្នកត្រូវការ ហើយស្នើសុំឱ្យការីទូរសព្ទ ទូរសព្ទទៅសាលារៀន។ ពេលនោះការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ ដើម្បីជួយអ្នកក្នុងការសន្ទនារបស់អ្នក។ អ្នកនឹងមិនត្រូវគេគិតថ្លៃសម្រាប់សេវាកម្មនេះទេ។